# ការធានារ៉ាប់រងភាពអត់ការងារធ្វើកាលីហ្វ័រញ៉ា និងសិទ្ធិភាសារបស់អ្នក

ប្រសិនបើអ្នកមានសិទ្ធិទទួលបាន unemployment insurance (ការធានារ៉ាប់រងភាពអត់ការងារធ្វើ) (UI) នៅរដ្ឋ កាលីហ្វ័រញ៉ា
ហើយជាចម្បងប្រើភាសាផ្សេងក្រៅពីភាសាអង់គ្លេស
អ្នកគួរតែដឹងអំពីសេវាកម្មភាសាថ្មី និងដែលមានស្រាប់នៅ Employment Development Department (នាយកដ្ឋានអភិវឌ្ឍន៍ការងារ/(EDD) ដែលគ្រប់ គ្រងអត្ថប្រយោជន៍ UI ។

អ្នកមានសិទ្ធិទទួលបានសេវាកម្មភាសាពី **EDD** ដូច្នេះអ្នកអាចចូលប្រើការទាមទារ **UI** និងការទទួលប្រាក់របស់អ្នកដោយផ្ទាល់។ អ្នកមិនគួរបង់ប្រាក់ឱ្យនរណាម្នាក់ដើម្បីដោះស្រាយការទាមទារ UI របស់អ្នកទេ។ ការប្រើប្រាស់សេវាកម្មឯកជន នឹងមិនមានលទ្ធផលក្នុងការលឿនជាងមុនទេ ហើយអាចធ្វើឱ្យអ្នកប្រឈមនឹងហានិភ័យនៃការក្លែងបន្លំ។

នៅពេលអ្នកបើកការទាមទារ **UI** អ្នកមានសិទ្ធិ៖

- ស្នើសុំ និងទទួលសេវាកម្មជាភាសាដែលអ្នកពេញចិត្ត នៅពេលអ្នកទាក់ទងជាមួយ បុគ្គលិក EDD តាមទូរសព្ទ ឬដោយផ្ទាល់តាមរយៈបុគ្គលិកដែលនិយាយ ច្រើនភាសា ឬអ្នកបកប្រែដែលមានជំនាញវិជ្ជាជីវៈ។
    - ទូរស័ព្ទទៅ ១-៨០០- ៣០០- ៥៦១៦ ហើយស្នើសុំការបកប្រែជាភាសាដែលអ្នក ពេញចិត្ត។
- ប្រសិនបើការបកប្រែមិនអាចធ្វើទៅបាននៅពេលអ្នកស្វែងរកសេវា EDD ត្រូវតែទាក់ទងអ្នកជាភាសាដែលអ្នកពេញចិត្តក្នុងរយៈពេល ៥ ថ្ងៃធ្វើការ ដោយមានករណីលើកលែងមានកំណត់។

អ្នកក៏មានសិទ្ធិក្នុងការ៖

- ស្នើសុំឯកសារ UI អាយេបកប្រែជាភាសាដែលអ្នកពេញចិត្ត។
- ឱ្យឯកសារ UI អានឮៗតាមរយៈបុគ្គលិកពហុភាសា ឬអ្នកបកប្រែដែលមានជំនាញវិជ្ជាជីវៈជាភាសាដែលអ្នកបានចុះហត្ថលេខា ឬជាភាសានិយាយដែលអ្នក ពេញចិត ទោះបីជាអ្នកបានទទួលការបកប្រែជាលាយលក្ខណ៍អក្សរក៏ដោយ។ ប្រសិនបើអ្នកមានចម្ងល់ សូមសួរបុគ្គលិក EDD សម្រាប់ការបំភ្លឺ។

ចាប់ផ្ដើមរដូវក្ដៅឆ្នាំ ២០២២៖

- អ្នកនឹងអាចកត់សម្គាល់ភាសាសរសេរ និងនិយាយ ឬសញ្ញាដែលអ្នកពេញចិត្ត ដោយផ្ទាល់នៅក្នុងការទាមទារ UI របស់អ្នក។
- បុគ្គលិកកម្មវិធី UI នឹងតម្រូវឱ្យពិនិត្យមើលចំណូលចិត្តភាសានៅក្នុងការទាមទារ របស់អ្នក និងផ្ដល់សេវាកម្មភាសាដោយមិនចាំបាច់ស្នើសុំពួកគេជាមុន។

ចាប់ផ្ដើមរដូវរងាឆ្នាំ ២០២២៖

- អ្នកនឹងអាចចូលប្រើឯកសារ UI មូលដ្ឋាន និងការជូនដំណឹងដែលត្រូវបានបកប្រែជាភាសាខ្មែរតាមរយៈគេហទំព័រ www.EDD.ca.gov។

សូមចងចាំ៖ អ្នកមានសិទ្ធិស្នើសុំសេវាកម្ម **UI** ជាភាសាណាមួយដែលអ្នកងាយស្រួលប្រើបំផុត ទោះបីជាភាសារបស់អ្នកមិនបង្ហាញនៅលើគេហទំព័ររបស់ EDD ឬការជូនដំណឹងផ្សេងទៀតក៏ដោយ។ ទូរស័ព្ទទៅ ១-៨០០- ៣០០- ៥៦១៦ ហើយស្នើសុំសេវាកម្មជា ភាសាដែលអ្នកពេញចិត្ត។

---

សូមចែករំលែកខិត្តប័ណ្ណនេះជាមួយសហគមន៍របស់អ្នក។ EDD កំពុងបន្តកែសម្រួលសេវាកម្មភាសាដោយផ្អែកលើមតិប្រតិកម្មពីអ្នកគាំទ្រនិងសហគមន៍ដូចរបស់អ្នក។

ប្រសិនបើអ្នកមានការលំបាកក្នុងការទទួលបានសេវាកម្ម UI ជាភាសាដែលអ្នកពេញចិត្ត ឬប្រសិនបើអ្នកមានគំនិតដើម្បីកែលម្អការចូលប្រើភាសា សូមទាក់ទង៖

- Asian Americans Advancing Justice - Asian Law Caucus (ការជំរុញយុត្តិធម៌ - ការប្រជុំច្បាប់អាស៊ី): (៤១៥) ៨៩៦-១៧០១
- California Rural Legal Assistance, Inc. (កាលីហ្វ័រញ៉ាជំនួយផ្នែកច្បាប់ជនបទ) (CRLA): (៦៦១) ៨៥៤-៣៨៣៩
- Center for Workers' Rights (មជ្ឈមណ្ឌលសិទ្ធិកម្មករ): (៩១៦) ៩០៥-១៦២៥
- Legal Aid Foundation of Los Angeles (មូលនិធិជំនួយផ្នែកច្បាប់នៃទីក្រុងឡូសអាន់ជ័រលេស) (LAFLA): (៨០០) ៣៩៩-៤៥២៩